48

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តសៀមរាប

-សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៣៤៩
ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧
-សំណុំរឿងជំនុំជម្រះលេខៈ ២៦២
ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨
-សាលក្រមព្រហ្មទណ្ឌលេខៈ ៦៦ "ខ"
ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូង ខេត្តសៀមរាប**

បានបើកសវនាការជាសាធារណៈនៅនាទីសាលាដំបូងខេត្តសៀមរាប
សាលសវនាការលេខ២B នាថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ វេលាព្រឹក។
កាលបរិច្ឆេទប្រកាសសាលក្រមជាសាធារណៈ
នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨។

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

ដើម្បីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌលេខៈ ១៣៤៩ ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទៈ

ឈ្មោះ [redacted] រីៈ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ កើតនៅភូមិអណ្តូងស្នាយ ឃុំអណ្តូងស្នាយ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ទីលំនៅមុនពេលចាប់ខ្លួន [redacted]ត្តកំពង់ចាម នៅលីវ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ទោសពីមុន គ្មាន។ (ក្នុងឃុំ)

លេខឃុំខ្លួនៈ ១៦៤៣ ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧។

ត្រូវជាប់ចោទពីបទៈ អំពើលួចដោយមានស្ថានទម្ងន់ទោស និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិកោកកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ ,មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥០ នៃច្បាប់ស្តីពីអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ។



Scanned with CamScanner

-លោក [redacted] ប៊ុនហាវ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វីរៈ ។

-លោក [redacted] ឈុនឡេង ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោ [redacted] វីរៈ ។

**ដើមបណ្តឹងរដ្ឋប្បវេណី**

១-ឈ្មោ [redacted] ចិន ភេទប្រុស អាយុ៦២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅភូមិកូនសាត់ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។

២-ឈ្មោះ [redacted] ប៊ុនរ៉ុង ភេទប្រុស អាយុ៤៦ឆ្នាំជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅភូមិរលួសខាងកើត ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ១៧០ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ១១១៥ (ង) ព.ស.ព្រស ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ៤៥៣ ពស.ព្រជ (ក) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់លោកប្រធានសាលាដំបូងខេត្តសៀមរាប។

**ឯអង្គហេតុកើតមានឡើងដូចតទៅៈ**

កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ០៨និង០០នាទី ស្ថិតនៅភូមិរកាកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានករណីអំពើលួចដោយមានស្ថានទម្ងន់ទោស ដែលបង្កឡើងដោយជនមិនស្គាល់អត្តសញ្ញាណ បានធ្វើសកម្មភាពកាច់សោរម៉ូតូចំនួន ០១គ្រឿង ម៉ាក សង់សេ១២៥ ស៊េរីឆ្នាំ២០១៧ ពណ៌ខ្មៅ គ្មានស្លាកលេខ ដែលជារបស់ជនរងគ្រោះឈ្មោះ [redacted] ន ភេទប្រុស អាយុ៦២ឆ្នាំ ហើយបានជិះគេចខ្លួនបាត់ ។ លុះក្រោយមក សមត្ថកិច្ចបានធ្វើការស្រាវជ្រាវ និងកំណត់មុខសញ្ញាឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] វីរៈ ភេទប្រុស អាយុ២៧ឆ្នាំ ព្រមទាំងដកហូតបានម៉ូតូខាងលើ និងអាវុធខ្លីចំនួន ០១ដើម ។

តំណាងអយ្យការនាពេលសវនាការ បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការ តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ជនជាប់ចោទបានសារភាពពិតជាមានអំពើលួចដោយមានស្ថានទម្ងន់ទោសប្រាកដមែន សូមតម្កល់បទចោទប្រកាន់ដូចនៅក្នុងដីកាសន្និដ្ឋានស្ថាពរលេខៈ ១៧០ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ របស់ អយ្យការអមសាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល។

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ លោក [redacted] ឈុនឡេង បានធ្វើសេចក្តីសន្និដ្ឋានថាៈ កូនក្តីខ្លួនបានសារភាពទោសកំហុស គឺសកម្មភាពកន្លងមកមានគ្នាចំនួន ០៤នាក់ តែពេលនេះទទួលតែពីរនាក់ទេ ដោយការធ្វើសកម្មភាព ឲ្យកូនក្តីខ្លួនជិះមកមុន ហើយពួកគេជិះតាមពីក្រោយទាន់ឲ្យទាំងម៉ូតូ និងអាវុធមកកូនក្តីរបស់ខ្លួន ។ ចំពោះសកម្មភាពកូនក្តីខ្លួន គឺទើបតែប្រព្រឹត្តបានម្តង ដូច្នេះស្នើសុំតុលាការផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន ។



Scanned with CamScanner

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ លោក [redacted] ប៊ុនហាវ បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីរបស់ខ្លួនបានសារភាពកំហុស ស្នើសុំតុលាការមេត្តាពិចារណាបន្ធូរបន្ថយទោស ។

-បានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]វីរៈ

-បានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន

-បានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ប៊ុនរ៉ុង

-បានពិនិត្យភស្តុតាងនានា

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

**ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**យល់ឃើញថា**

-កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ថិតនៅត្រង់ចំណុចភូមិរកាកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ឈ្មោះ [redacted]វីរៈ ពិតជាបានធ្វើសកម្មភាពប្រើប្រាស់អាវុធដោយខុសច្បាប់ និងលួចកាច់សោរកម៉ូតូមួយគ្រឿង ម៉ាកសង់សេ១២៥ ស៊េរីឆ្នាំ២០១៧ ពណ៌ខ្មៅ គ្មានស្លាកលេខ ដែលជារបស់ជនរងគ្រោះឈ្មោះ [redacted] ចិន ប្រាកដមែន ។

- ជនជាប់ចោទខាងលើ ពិតជាមានសមត្ថភាព មានស្មារតី និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវទង្វើដែលខ្លួនបានប្រព្រឹត្ត ដូចការចោទប្រកាន់បញ្ជូនមកជម្រះរបស់ចៅក្រមស៊ើបសួរ តាមដីកាដំណោះស្រាយលេខ: ១១១៥ (ង) ព.ស.ព្រស ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តសៀមរាប ។

-តាមភស្តុតាង និងការពិនិត្យលើកិច្ចស៊ើបសួរ រហូតដល់ជម្រះមិនមានអង្គហេតុអ្វីប្រែប្រួលទេ។ ដូចនេះជនខាងលើពិតជាមានចេតនាក្នុងការប្រព្រឹត្តបទល្មើសនោះយ៉ាងពិតប្រាកដមែន តាមមាត្រា០៤ នៃក្រមព្រហ្មទណ្ឌ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះឈ្មោះ [redacted] ចិន ប៉ុន្តែជនរងគ្រោះបានទទួលទ្រព្យសម្បត្តិដែលបាត់បង់ពីជនជាប់ចោទរួចហើយ ហើយមិនបានចូលមកឆ្លើយទាមទារសំណងការខូចខាតនៅដំណាក់កាលស៊ើបសួរទេ ។ ដូចនេះតុលាការគប្បីមិនសម្រេចអំពីសំណងរដ្ឋប្បវេណីទេ។

-ចំពោះវត្ថុតាងរួមមាន: ទូរស័ព្ទដៃម៉ាក Camfone Model: P600 ពណ៌បៃតង ចំនួន ០១ គ្រឿង ,នាឡិកាដៃចំនួន ០១ និងសោរម៉ូតូម៉ាកហុងដា ចំនួន ០១ គប្បីតុលាការសម្រេចប្រគល់ឲ្យម្ចាស់ដើមឈ្មោះ [redacted]វីរៈ វិញ ។

- មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted]វីរៈ ភេទប្រុស អាយុ២៧ឆ្នាំ ពីបទ៖ អំពើលួចដោយមានស្ថានទម្ងន់ទោស និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិរកាកំបុត ឃុំត្រពាំងធំ



Scanned with CamScanner

ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ ,មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និង មាត្រា៤៩០ នៃច្បាប់ស្តីពីអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

**ហេតុដូច្នេះសម្រេច÷**

១-ផ្តន្ទាទោសឈ្មោះ [redacted] រីះ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ (ដូចមានសាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០៧ (ប្រាំពីរ) ឆ្នាំ ។

ពីបទ៖ អំពើលួចដោយមានស្ថានទម្ងន់ទោស និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិរកាកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ ,មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៩០ នៃច្បាប់ស្តីពីអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

២-វត្ថុតាងរួមមានទូរស័ព្ទដៃម៉ាក Camfone Model: P600 ពណ៌បៃតង ចំនួន ០១គ្រឿង , នាឡិកាដៃចំនួន ០១ និងសោរម៉ូតូម៉ាកហុងដា ចំនួន ០១ ត្រូវប្រគល់ឲ្យម្ចាស់ដើមឈ្មោះ [redacted] រីះ វិញ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រីះ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន និងឈ្មោះ [redacted] ប៊ុនរ៉ុង បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខានិងត្រា: [redacted] | ហត្ថលេខានិងត្រា: [redacted] | ហត្ថលេខានិងត្រា: [redacted] | ហត្ថលេខានិងត្រា: [redacted] |

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ០៦កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

សៀមរាប, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner